**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរទន្លេសាប**
គណៈកម្មាធិការលទ្ធកម្ម
លេខ : ...០២១...អទស.សជណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការខារផ្គត់ផ្គង់សម្ភារៈការិយាល័យ និងអនាម័យ ឆ្នាំ ២០១៨

អាជ្ញាធរទន្លេសាប (ក្រសួងធនធានទឹក និងឧតុនិយម) សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា ៖ អាជ្ញាធរទន្លេសាប នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់សម្ភារៈការិយាល័យ និងអនាម័យ ឆ្នាំ ២០១៨ របស់អាជ្ញាធរទន្លេសាប ។

អាជ្ញាធរទន្លេសាប បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មអាជ្ញាធរទន្លេសាប (ក្រសួងធនធានទឹក និងឧតុនិយម) ដែលមានអាសយដ្ឋានអគារលេខ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទង ០២៣ ៧២៧ ៤៥៤, ០៨០ ៥៥៥ ៥៨០) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង ៩:០០នាទីព្រឹក ថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០១៨ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង៩:០០ នាទីព្រឹក ថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ៧ ៨ ៧ ១ ៩ ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៨
ន. **ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហ៊ែល-តូនី**

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ